**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**
លេខ :..................អ.ជ.ប.ជ.អ.

ភ្នំពេញ. ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥

# របាយការណ៍
## ស្តីពី
## កិច្ចជួបពិភាក្សាការងាររវាង ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង Dr. Robert Newman នាយកអង្គការ USCDC ប្រចាំកម្ពុជា



កាលពីវេលាម៉ោង៩:០០ព្រឹក ថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ២០១៥នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានអនុញ្ញាតឲ្យលោកវេជ្ជ. **រ៉ូប៊ើត ញូម៉ែន** នាយកអង្គការUSCDC ប្រចាំកម្ពុជាចូលជួបសំដែងការគួរសម និងពិភាក្សាការងារ ដោយផ្តោតសំខាន់លើបច្ចុប្បន្នភាពការងារប្រយុទ្ធនឹងជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជា ក្នុងពេលដែលលោកទើបនឹងទទួលការងារជាប្រធានថ្មីរបស់អង្គការUSCDC ។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសំដែងនូវការស្វាគមន៍ និងបានជម្រាបជូនភ្ញៀវពីស្ថានភាពទូទៅនៃការរាលដាលមេរោគអេដស៍នៅកម្ពុជា រួមជាមួយបច្ចុប្បន្នភាពស្តីពីវឌ្ឍនៈភាព សមិទ្ធិផល និងប្រសិទ្ធភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាផងដែរ។ ទន្ទឹមនឹងនេះ **ឯកឧត្តមប្រធាន**ក៏បានផ្ញើរសារតាមរយៈលោកវេជ្ជ **រ៉ូប៊ើត ញូម៉ែន** នូវអំណរគុណក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា

និងប្រជាពលរដ្ឋកម្ពុជាជូនចំពោះប្រជាជនសហរដ្ឋអាមេរិកដែលបានផ្តល់ការគាំទ្រនូវថវិកា និងបច្ចេកទេសមកប្រទេសកម្ពុជាកន្លងមកជាពិសេសក្នុងវិស័យសុខាភិបាល។ ខ្លឹមសារសំខាន់ៗដែល **ឯកឧត្តមប្រធាន** បានជម្រាបជូនភ្ញៀវគឺសង្កត់ធ្ងន់លើចំណុចមួយចំនួនដូចខាងក្រោម៖

- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានកំពុងបង្កើននូវភាពម្ចាស់ការ ដោយបានចូលរួមចំណែកផ្តល់ថវិកាសម្រាប់ការទិញឱសថប្រឆាំងនឹងមេរោគអេដស៍ (ARV) ចំនួន៣.៧លានដុល្លាសម្រាប់រយៈពេល៣ឆ្នាំ(ចំនួន១លានដុល្លានៅឆ្នាំ២០១៥, ចំនួន១.២លានដុល្លានៅឆ្នាំ២០១៦ និងចំនួន១.៥លានដុល្លានៅឆ្នាំ២០១៧)។
- ក្នុងបរិការណ៍នៃការថយចុះនៃជំនួយបរទេស អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានខិតខំស្វែងរកការគាំទ្រពីរាជរដ្ឋាភិបាល នូវសំណើថវិកាចំនួន៤លានដុល្លាក្នុងខ្ទង់ថវិកាជាតិឆ្នាំ២០១៦ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ថ្នាក់ក្រោមជាតិលើការងារដែលមិនមែនសុខភាពជំនួសឱ្យសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលខ្លះដែលអស់ថវិកា។
- បានជំរុញលើកទឹកចិត្តឲ្យមានការចូលរួមធ្វើតេស្តឈាមរកមេរោគអេដស៍ ជាពិសេសពីសំណាក់កម្មកររោងចក្រ និងជនចំណាកស្រុក។
- រៀបចំឲ្យមានការចាត់តាំងអ្នកទទួលខុសត្រូវស្មគ្រ័ចិត្ត ឬជាប់កិច្ចសន្យានៅតាមមូលដ្ឋានភូមិ ឃុំសម្រាប់ជួយពិនិត្យតាមដាន និងជំរុញប្រជាជនប្រឈមមុខមកស្វែងរកសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍ឲ្យទទួលសេវាព្យាបាលបានទៀងទាត់។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍កំពុងតែផ្តោតការងារសំខាន់ ទៅលើយុវវ័យជំនាន់ក្រោយដែលកំពុងតែប្រឡូកនឹងការរួមភេទ (១៣% ក្នុងចំណោមយុវវ័យអាយុចាប់ពី១៤ឆ្នាំ) ស្របពេលដែលការយល់ដឹងរបស់ពួកគេស្តីពីជំងឺអេដស៍ក៏មានការធ្លាក់ចុះគួរឲ្យបារម្ភ។
- បន្តសហការជាមួយក្រសួងសុខាភិបាល ក្នុងការបង្ការការចម្លងមេរោគអេដស៍តាមរយៈ គ្រូពេទ្យដែលគ្មានលិខិតអនុញ្ញាតត្រឹមត្រូវ ដើម្បីជៀសវាងការលេចឡើងហេតុអាក្រក់ដូចករណីឃុំរការខេត្តបាត់ដំបង។

ជាការឆ្លើយតបលោកវេជ្ជ. **រ៉ូប៊ីន ខូម៉ែន** បានសំដែងនូវអំណរគុណចំពោះ**ឯកឧត្តមប្រធាន**ដែលបានផ្តល់ឱកាសឲ្យរូបលោកបានចូលជួបសំដែងការគួរសម និងបានជម្រាបជូននូវគម្រោងភាពជាដៃគូរបស់អង្គការUSCDC ជាមួយស្ថាប័នរដ្ឋាភិបាលចំនួនបីគឺ NIPH NCHADS និងក្រសួងសុខាភិបាល។ លោកវេជ្ជបណ្ឌិតក៏បានធ្វើការចាប់អារម្មណ៍លើចំនុចមួយចំនួនដូចខាងក្រោម៖

- លោកវេជ្ជបណ្ឌិតសូមសំដែងនូវការអបអរ និងវាយតម្លៃខ្ពស់ចំពោះប្រទេសកម្ពុជាដែលបានទទួលនូវជោគជ័យពិតប្រាកដលើការកាត់បន្ថយការចម្លងមេរោគ និងជំងឺអេដស៍។
- ថ្វីត្បិតតែប្រទេសកម្ពុជាស្ថិតនៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប(lowest middle income country) កម្ពុជានៅតែត្រូវការថវិកាជាចាំបាច់សម្រាប់បន្តប្រីភាពកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ បើពុំដូច្នោះទេ ការរាលដាលមេរោគអេដស៍នឹងអាចវិលត្រឡប់មកវិញជាក់ជាមិនខាន។
- ក្នុងនាមជាដៃគូអភិវឌ្ឍន៍ ពួកគេត្រូវពិចារណាពីការកាត់បន្ថយនូវហិរញ្ញប្បទានឲ្យបានស្របគ្នាទៅនឹងលទ្ធភាពផ្គត់ផ្គង់ហិរញ្ញប្បទានពីរាជរដ្ឋាភិបាលជាបណ្តើរៗ ស្របនឹងតម្រូវការនូវឆន្ទៈនយោបាយខ្ពស់។

- លោកវេជ្ជបណ្ឌិត សូមចូលរួមជាមួយនឹងប្រទេសកម្ពុជាក្នុងការបង្ហាញនូវការប្តេជ្ញាចិត្តប្រយុទ្ធនឹងជំងឺអេដស៍ឆ្ពោះទៅរកគោលដៅ៩០-៩០-៩០ ជាពិសេសឈានពីការគ្រប់គ្រងទៅរកការលុបបំបាត់ការឆ្លងទាំងស្រុង។
- លោកវេជ្ជបណ្ឌិតសូមគាំទ្រចំពោះការសិក្សាមួយនៅកម្ពុជាដែលបានវិភាគថា ការវិនិយោគនៅពេលបច្ចុប្បន្ននេះ នឹងផ្តល់នូវផលជាវិជ្ជមានខ្ពស់ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍នៅពេលអនាគតក្នុងកម្រិតចំណាយមួយដ៏តិចតួច។
- លោកវេជ្ជបណ្ឌិតក៏មានការព្រួយបារម្ភផងដែរ ចំពោះកម្រិតប្រាក់ខែទាបរបស់មន្ត្រីរាជការដែលជាបញ្ហាប្រឈមមួយផងដែរចំពោះអ្នកធ្វើការងារអេដស៍នៅតាមមណ្ឌលសុខភាពឬមណ្ឌលសុខភាព។
- លោកវេជ្ជបណ្ឌិតបានឯកភាព ចំពោះការលំបាកមួយចំនួនរបស់គម្រោងមូលនិធិសកលដែលមានគោលការណ៍អនុវត្តដោយឡែកពីការអនុវត្តរបស់កម្ពុជា តែពេលខ្លះគម្រោងមូលនិធិសកល ក៏កំពុងទទួលរងនូវសម្ពាធពីម្ចាស់ជំនួយ ដែលតម្រូវឲ្យការអនុវត្តមានតម្លាភាពខ្ពស់ផងដែរ ដោយមិនបានគិតពីស្ថានភាពជាក់ស្តែងរបស់ប្រទេសនីមួយៗ។
- USCDCប្រចាំកម្ពុជានឹងបន្តកិច្ចសហការជានិច្ច និងរៀងរាល់ពេលដែលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវការ។

មុននឹងបញ្ចប់កិច្ចពិភាក្សា **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានបញ្ជាក់បន្ថែមថា៖
- រាជរដ្ឋាភិបាលកម្ពុជាយល់បានច្បាស់ពីបញ្ហាបៀវត្ស ដោយរាជរដ្ឋាភិបាលបានចំណាយថវិកាជាតិរហូតដល់ទៅប្រមាណ៤៩.៥% នៃចំណាយចរន្តសម្រាប់ប្រាក់បៀវត្សមន្ត្រីរាជការដែលជាការចំណាយខ្ពស់បំផុតសម្រាប់ឆ្នាំ២០១៥ និងខិតខំបន្តដំលើងឲ្យបានទាបបំផុតត្រឹមចំនួន២៥០ដុល្លាក្នុងមួយខែនៅឆ្នាំ២០១៨។
- ដៃគូអភិវឌ្ឍន៍ ដោយឡែកមូលនិធិសកលគួរពិចារណាក្នុងការបន្តប្រាប់ឧបត្ថម្ភបន្ថែមតាមដែលអាចធ្វើទៅបានដើម្បីចូលរួមបំពេញគម្លាតខ្វះខាតនេះ។
- ចំពោះបញ្ហាតម្លាភាព ក្នុងនាមជាប្រធានCCC **ឯកឧត្តម**បានខិតខំសម្របសម្រួលគោលការណ៍នៃការអនុវត្តការចំណាយរបស់គម្រោងមូលនិធិសកលឱ្យបានសមស្រប ជាមួយនឹងគោលការណ៍ថវិកាជាតិ។ លើសពីនេះកម្ពុជាមានអង្គភាពប្រឆាំងអំពើពុករលួយសម្រាប់ការឃ្លាំមើលដ៏សំខាន់។
- សូមឲ្យUSCDCប្រចាំកម្ពុជាបន្តកិច្ចសហការជាមួយកម្មវិធីជាតិជា បន្តទៀតក្នុងការប្រើប្រាស់គោលដៅតែមួយ ប្រព័ន្ធតែមួយ និងសម្លេងតែមួយ។

ជំនួបពិភាក្សាត្រូវបានបញ្ចប់នៅវេលាម៉ោង១០:០០នាថ្ងៃខែឆ្នាំដដែល ប្រកបដោយភាពស្និទស្នាល និងប្តេជ្ញាបន្តនូវកិច្ចសហប្រតិបត្តិការប្រកបដោយការយោគយល់ខ្ពស់៕

បានឃើញ និង ឯកភាព
ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអ.ជ.ប.ជ.អ

អៀង_មូលី

អ្នកធ្វើរបាយការណ៍

ឈឹម មិនដារ៉ែត